**សកម្មភាព** ៖ រឿងម៉ូនីមេខាឡា និងរបាំ

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**សិក្សាសង្គម**

ចម្រៀង និងតន្ត្រី(ចំណេះដឹងបច្ចេកទេស ការច្នៃប្រឌិត និងបទពិសោធន៍តន្ត្រី)

ការលើកតម្កើនវប្បធម៌(ការលើកតម្កើនវប្បធម៌របស់ខ្លួន)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)** ច្រៀងចំរៀង និងធ្វើកាយវិការតាមបទចម្រៀងបាន។

ប្រាប់បានពីសកម្មភាពខ្លះៗពីប្រពៃណីជាតិ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ពូថៅក្រដាស និងត្បូងក្រដាស (ពូថៅ គឺសម្រាប់ក្មេងប្រុស និងត្បូងសម្រាប់ក្មេងស្រីៗ)

**ការរៀបចំ** ៖ រៀនពីរឿង មើលគេរាំ ជ្រើសរើសបទចម្រៀងសម្រាប់ចាក់ឱ្យក្មេងៗរាំ។ ធ្វើពូថៅក្រដាស និងត្បូងក្រដាសឱ្យរួចរាល់សម្រាប់ក្មេងៗទាំងអស់គ្នា ម្នាក់មួយៗ។

សូមមើលYouTubeទាំងនេះ:(រឿង, ចម្រៀង)។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងនិទានរឿងម៉ូនីមេខាឡា និងរាំ ឱ្យកូនៗស្តាប់ទាំងអស់គ្នា។
2. តើកូនៗស្គាល់ឥន្ទធនូដែរឬទេ? ចាស/បាទស្គាល់។
3. អ្នកគ្រូនឹងប្រាប់កូនៗអំពីរឿងរបស់ឥន្ទធនូដែលត្រូវការព្រះអាទិត្យ និងទឹកភ្លៀង ។
4. ប្រាប់ក្មេងៗថា៖ រឿងម៉ូនីមេខាឡា គឺជារឿងបុរាណខ្មែរ ដែលនិយាយអំពី ស្តេចភ្លៀង និងរបាំខ្មែរ។

5. ចាក់បទចម្រៀងឱ្យលឺសម្លេងតិចៗនៅពីក្រោយ ដូចជាអ្នកអានរឿងឱ្យក្មេងៗស្តាប់អញ្ចឹងដែរ។
6. ចំណុចសំខាន់នៃរឿងនេះគឺការរាំ (ឲ្យក្មេងៗស្រមើលស្រមៃថាគួរតែរាំបែបណា)។
7. ឱ្យក្មេងៗចាប់គូរប្រុសម្នាក់ និងក្មេងស្រីម្នាក់
8. ចែកពូថៅក្រដាស ទៅក្មេងប្រុសៗ និងត្បូងក្រដាសក្មេងស្រី។
9. ប្រាប់ក្មេងៗថាមិនត្រូវប៉ះគ្នានោះទេ ប៉ុន្តែត្រូវវាយឱ្យខ្លាំងៗដើម្បីឱ្យវាលឺសម្លេង។ នេះគឺជាការរាំ មិនមែនជាល្បែងទេ ឬជាការប្រកួតជាក់ស្តែងនោះឡើយ។
10. ចាក់បទចម្រៀងលឺៗ ហើយឱ្យក្មេងៗបង្កើតក្បាច់រាំដែលអាចពិពណ៌នាពីរឿង។
11. នេះគឺជាគំរូការរាំ ហើយក្មេងៗអាចតុបតែងមុខមាត់ដោយខ្លួនឯងបាន។

មានក្បាច់រាំដូចជា៖

- សំពះគ្រូ
- ប្រមូលទឹកសន្សើម
- សំពះគ្រូម្តងទៀត និងចាប់យកក្រដាសដែលជាវត្ថុរាងៗខ្លួន
- ក្មេងប្រុសសុំគ្រាប់ត្បូងពីក្មេងស្រី
- ក្មេងស្រីគ្រវីក្បាលរបស់ពួកគេ
- ក្មេងប្រុសព្យាយាមដេញយកត្បូងហ្នឹង
- ក្មេងប្រុសគប់ពូថៅក្រដាសរបស់ខ្លួន
- ក្មេងស្រី គប់ត្បូងត្រឡប់ទៅវិញ
- ក្មេងប្រុសសម្តែងធ្វើជាខ្វាក់
- ក្មេងស្រីរាំឆ្ងាយពីក្មេងប្រុស

12. អនុញ្ញាតប្រសិនបើក្មេងៗចង់បង្ហាញការរាំរបស់ពួកគេនៅក្នុងថ្នាក់។